**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ អាងទឹកជ្រោយចេក រយៈពេល ៥ ឆ្នាំ (២០១៧-២០២២)

រៀបចំដោយរដ្ឋបាលជលផល ឧត្ថម្ភដោយ FAO
ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ អាងទឹកជ្រោយចេក |
| ភូមិ | ៖ វាលគ្រៀល ទួលចំបក់ ប្រថង ទ្រាន តាខុន ត្រពាំងតាសុក ប៉ែន និងទួលក្រាច |
| ឃុំ | ៖ ទ្រាន |
| ស្រុក | ៖ កំពង់សៀម |
| ខេត្ត | ៖ កំពង់ចាម |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អាងទឹកជ្រោយចេក
# រយៈពេល ៥ ឆ្នាំ (២០១៧-២០២២)

រៀបចំដោយរដ្ឋបាលជលផល ឧបត្ថម្ភដោយ FAO
ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | អាងទឹកជ្រោយចេក |
| ភូមិ | ៖ | វាលគ្រៀល ទួលចំបក់ ប្រថង ទ្រាន តាខុង ត្រពាំងតាសុក ប៉ែន និងទួលត្រាច |
| ឃុំ | ៖ | ទ្រាន |
| ស្រុក | ៖ | កំពង់សៀម |
| ខេត្ត | ៖ | កំពង់ចាម |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អាងទឹកជ្រោយចេក
# រយៈពេល ៥ ឆ្នាំ (២០១៧-២០២២)

រៀបចំដោយរដ្ឋបាលជលផល ឧបត្ថម្ភដោយ FAO
ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | អាងទឹកជ្រោយចេក |
| ភូមិ | ៖ | វាលគ្រៀល ទួលចំបក់ ប្រថង ទ្រាន តាខុង ត្រពាំងតាសុក ប៉ែន និងទួលត្រាច |
| ឃុំ | ៖ | ទ្រាន |
| ស្រុក | ៖ | កំពង់សៀម |
| ខេត្ត | ៖ | កំពង់ចាម |

# មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**

**២- អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ

ខ- មុខរបរ

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក- ទីតាំង

ខ- ដែននេសាទ

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

ឃ- ធនធានជលផល

**៤- ការធ្វើនេសាទ**

ក- អ្នកនេសាទ

ខ- ឧបករណ៍នេសាទ

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក- ទស្សនៈវិស័យ

ខ- គោលបំណង

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គ២- ផែនការកែលម្អដែននេសាទ

គ៣- ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល

គ៦- ផែនការប្រជុំប្រចាំខែនិងសម្ភារៈអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ

គ១០- ផែនការបង្កើតក្រុមតណាទានដើម្បីបង្កើនមុខរបរ

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ

គ១២- ផែនការសាងសង់ស្តង់សហគមន៍នេសាទ

គ១៣- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ឃ. ផែនការយុទ្ធសាស្ត្រ

- តារាងកម្មវិធីការងារ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទអាងទឹកជ្រោយចេក បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០២ ហើយបានរៀបចំបោះឆ្នោតឡើងវិញនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៨ ។

សហគមន៍នេសាទអាងទឹកជ្រោយចេក មានទីតាំងស្ថិតនៅភូមិវាលគ្រៀល ទួលចំបក់ ទួលត្រាច ប្រថង ទ្រាន ត្រពាំងតាសុក ប៉ែន និងភូមិតាខុង ឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ដែលមានសមាជិកសហគមន៍នេសាទសរុបចំនួន១៦៥នាក់ ប្រុស១៥១នាក់ ស្រី១៤នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន១៦៥គ្រួសារ។ សហគមន៍នេសាទអាងទឹកជ្រោយចេក ធ្វើមហាសន្និបាតកំណើតដំបូងមានគណៈកម្មការចំនួន០៥នាក់ ស្រី០១នាក់និងមានក្រុមល្បាតចំនួន១២នាក់ ហើយឆ្នាំ២០១៤ បានធ្វើមហាសន្និបាតលើកទី២ មានគណៈកម្មការចំនួន១១នាក់ ស្រីគ្មាន ។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិកនិងគណៈកម្មការ សហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍និងធ្វើផែនទី
- ស្នើសុំចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍ និងការពារព្រៃលិចទឹក
- បង្កើតកន្លែងអភិរក្សត្រីមេពូជនិងការពារកន្លែងអភិរក្សត្រីមេពូជ
- ចូលរួមសិក្ខាសាលាស្តីពីវឌ្ឍនភាពនៃដំណើរការអនុវត្តន៍ការគ្រប់គ្រងសហគមន៍នេសាទ
- ទស្សនៈកិច្ចសិក្សា (នៅប្រទេសវៀតណាមស្តីពីការចិញ្ចឹមត្រីនិងភ្ញាស់កូនត្រី)
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ស្រុក
- បង្កើតក្រុមមុខរបរ (ធនាគារគោ ការចិញ្ចឹមត្រី)
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២ អំពីប្រជាសាស្រ្ត និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្រ្ត

ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន៤.៨៨១នាក់ ប្រុស២.៤៣២នាក់ ស្រី២.៤៤៩នាក់ ក្នុងនោះ មានចំនួន១.៨២៥គ្រួសារ ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ៩៩,៦៨% សាសនាត្រឹះ0,៣២%។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៣៣នាក់ ស្រីចំនួន៤នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៩៩នាក់ ស្រីចំនួន៧នាក់ កម្រិតមធ្យមសិក្សាចំនួន៣១នាក់ ស្រីចំនួន២នាក់ និងកម្រិតឧត្តមសិក្សាចំនួន២នាក់ ស្រីចំនួន១នាក់។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១៣នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន២នាក់ ស្រី០នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៤នាក់ ស្រី២នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន២ នាក់ ស្រី១នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៣នាក់ ស្រី២នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

| | | |
|---|---|---|
| – ធ្វើនេសាទចំនួន៦៦ គ្រួសារ | | |
| – ធ្វើស្រែចំនួន១៣២ គ្រួសារ | ទំហំ២១៤ហិកតា | |
| – ធ្វើចំការចំនួន១១គ្រួសារ | ទំហំ៤,៥ហិកតា | |
| – ធ្វើវារីវប្បកម្មចំនួន១៦គ្រួសារ | ស្រះចំនួន៦ស្រះ | ទំហំ១៥មx២០ម x២,៥ម |
| | អាងចំនួន១០អាង | ទំហំ២មx១,៥មx១,២ម |
| – ដាំបន្លែចំនួន៥គ្រួសារ | ទំហំ១ហិកតា | |

- ជាងផ្ទះចំនួន ១គ្រួសារ
- លក់ដូរចំនួន១៥គ្រួសារ
- កម្មករ៧គ្រួសារ
- មន្ត្រីរាជការ៤គ្រួសារ
- ចិញ្ចឹមសត្វ៤៥គ្រួសារ ។
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៦.៤៨៤.០០០រៀល ។

## ៣ កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍អាងទឹកជ្រោយចេក ជាដែននេសាទទឹកសាប ខ្ពង់រាបនៃសណ្ដរដងទន្លេមេគង្គមានស្ថានភាពជាអាងទឹក ក្នុងខេត្តកំពង់ចាម មានផ្ទៃក្រឡាទំហំ១៩៣ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងភូមិព្រៃគួយ ឃុំស្រេក ស្រុកកំពង់សៀម ខេត្តកំពង់ចាម
- ខាងត្បូងទល់នឹងភូមិវាលគ្រៀល ឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម
- ខាងកើតទល់នឹងទំនប់ជ្រោយចេក ឬនិង ផ្លូវលំក្នុងឃុំទ្រាន និងឃុំស្រេក
- ខាងលិចទល់នឹងខ្ពង់រាបនៃឃុំទ្រាន និងឃុំស្រេក

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទអាងទឹកជ្រោយចេកចំនួន១អាង អូរចំនួន១អូរ គឺ៖

| | | |
|---|---|---|
| អាងទឹកជ្រោយចេក | ទំហំ ៨០,១ ហិកតា | ពេញមួយឆ្នាំ |
| អូរ(យាង) | ទំហំ ១.៣៥៦ម x៥ម | កក្កដា ដល់ មីនា |

ដីទំនាបលិចទឹកមានទំហំសរុប ១១២,២២ ហិកតា។

គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

អាងទឹកជ្រោយចេក ទំហំ ១០០ម x ១០០ម ពេញមួយឆ្នាំ ។

ឃ. ធនធានជលផល

- ប្រភេទត្រី ៖

ត្រីរស់ ត្រីឆ្តោរ ត្រីក្អែក ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីឆ្ពោង ត្រីឆ្លូញ ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ធ្រប់ ត្រីខ្មាន់ ត្រីអណ្តែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ញឹង ត្រីអំពិលទុំ ត្រីផ្កាស្មៅ ត្រីបណ្តូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាវក្តាម ត្រីលលកសរ ត្រីឆ្ពិន ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រុស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីកញ្ជនដៃ កំពិស ។ល។

- ប្រភេទវារីសត្វ ៖

អណ្តើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ក្តាម អន្ទង់ ខ្ទៅគូចស្រួច ខ្ទៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖

ដើមថ្លើមអណ្តើក ខ្លបយក្ស(អូយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លេង អញ្ចាញ ត្នួ ស្នែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ខ្នាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្មើក អំពាក់ទឹក ស្លាបទា កន្ទាំងហៃ ស្មោ ស្លូត បន្លាឃ្លេ ថ្វាន់ ស្នួលទឹក ច្រកែង ប្រផេញ ផ្តៅ ភ្អែកព្រាប វល្លិ៍អណ្តាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចម៍មាន់ ព្រលិតដូង រំចង់ ស្គន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបូង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៦៦នាក់ ស្រី១៤នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មាន ចំនួន៩៤៣នាក់ ស្រី១៥២នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៦៧នាក់ស្រី១៥នាក់។

ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ត្បូង | ៦៦ | ៣៥០-១.៤០០ម/គ្រួសារ | ៥៧.៧៥០ម៉ែត្រ | ពេញមួយមួយឆ្នាំ |
| លប | គ្រឿង | ២ | ៤០គ្រឿង/គ្រួសារ | ១២០គ្រឿង | ខែវិច្ឆិកា ដល់ ខែមករា |
| សំណាញ់ | វង់ | ១៧ | ១វង់/គ្រួសារ | ១៧វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៨ | ៥០០ផ្លែ/គ្រួសារ | ៤.០០០ផ្លែ | ខែសីហា ដល់ ខែវិច្ឆិកា |
| សន្ទូចបង្កៃ | ផ្លែ | ៤ | ២០ផ្លែ/គ្រួសារ | ៨០ផ្លែ | ខែសីហា ដល់ ខែវិច្ឆិកា |

| | | | | | |
|---|---|---|---|---|---|
| លាន់ | គ្រឿង | ៣ | ២០-៥០គ្រឿង/គ្រួសារ | ១០៥គ្រឿង | ខែសីហា ដល់ ខែតុលា |
| ថ្នង(ដងដៃ) | គ្រឿង | ៥ | ១គ្រឿង/គ្រួសារ | ៥គ្រឿង | ខែសីហា ដល់ ខែតុលា |
| ទ្រូ | គ្រឿង | ៧ | ២គ្រឿង/គ្រួសារ | ១៤គ្រឿង | ខែសីហា ដល់ ខែវិច្ឆិកា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៤គ្រឿង | ១០០-៤០០គីឡូក្រាម | ៤,៥-៧សេះ |
| ទូកអ៊ុំ និងចែវ | ៣០គ្រឿង | ៥០-១០០គីឡូក្រាម | - |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ៩៤៣ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១៤១ | ៣៥០-១.៤០០ម/គ្រួសារ | ១២៣.៣៧៥ម៉ែត្រ | ពេញមួយមួយឆ្នាំ |
| លប | គ្រឿង | ១១ | ៤០គ្រឿង/គ្រួសារ | ៤៤០គ្រឿង | ខែវិច្ឆិកា ដល់ ខែមករា |
| សំណាញ់ | វង់ | ៩៧ | ១វង់/គ្រួសារ | ៩៧វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៤៥ | ៥០០ផ្លែ/គ្រួសារ | ២២.៥០០ផ្លែ | ខែសីហា ដល់ ខែវិច្ឆិកា |
| សន្ទូចបង្កៃ | ផ្លែ | ២៣ | ២០ផ្លែ/គ្រួសារ | ៤៦០ផ្លែ | ខែសីហា ដល់ ខែវិច្ឆិកា |
| លាន់ | គ្រឿង | ១៧ | ២០-៥០គ្រឿង/គ្រួសារ | ៥៩៥គ្រឿង | ខែសីហា ដល់ ខែតុលា |
| ថ្នង(ដងដៃ) | គ្រឿង | ២៨ | ១គ្រឿង/គ្រួសារ | ២៨គ្រឿង | ខែសីហា ដល់ ខែតុលា |
| ទ្រូ | គ្រឿង | ៣៩ | ២គ្រឿង/គ្រួសារ | ៧៨គ្រឿង | ខែសីហា ដល់ ខែវិច្ឆិកា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១២គ្រឿង | ១០០-៤០០គីឡូក្រាម | ៤,៥-៧សេះ |
| ទូកអ៊ុំ និងចែវ | ១៥៣គ្រឿង | ១០០-២០០គីឡូក្រាម | - |

– ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ក្បួង | ២០ | ៣៥០-១.៤០០ម/គ្រួសារ | ១៧.៥០០ម៉ែត្រ | ពេញមួយមួយឆ្នាំ |
| អួនអូសដៃ | វង់ | ៣ | ៥០-១០០ម/១វង់/គ្រួសារ | ២២៥ម/៧៥វង់ | ខែមីនា ដល់ ខែឧសភា |
| មងហ៊ុំ | វង់ | ១០ | ៣៥-៥០ម/គ្រួសារ | ៤២៥ម/១០វង់ | ខែមីនា ដល់ ខែមិថុនា |
| សន្ទូច | ផ្លែ | ៣ | ៥០០ផ្លែ/គ្រួសារ | ១.៥០០ផ្លែ | ខែសីហា ដល់ ខែវិច្ឆិកា |
| សន្ទូចបង្កៃ | ផ្លែ | ២ | ២០ផ្លែ/គ្រួសារ | ៤០ផ្លែ | ខែសីហា ដល់ ខែវិច្ឆិកា |
| សំណាញ់ | វង់ | ១៥ | ១វង់/គ្រួសារ | ១៥វង់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២គ្រឿង | ១០០-៥០០គីឡូក្រាម | ៤,៥-៩សេះ |
| ទូកអ៊ុំ និងចែវ | ១៥គ្រឿង | ១០០-២០០គីឡូក្រាម | - |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចំរុះ | ៣៤២គីឡូក្រាម | ៧៩៨ គីឡូក្រាម | ១.១៤០គីឡូក្រាម |
| ខ្ចៅ ខ្យង | ៧៥ គីឡូក្រាម | ១៧៥ គីឡូក្រាម | ២៥០គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក. ទស្សនៈវិស័យ ៖**

សហគមន៍នេសាទអាងទឹកជ្រោយចេក មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**ខ. គោលបំណង ៖**

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ដែលជាកន្លែងនេសាទគ្រួសារដោយរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

**គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| អាងទឹកជ្រោយចេក | ពេញមួយឆ្នាំ | មងរាយ | ៨០ម/គ្រួសារ | ៣០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | វិច្ឆិកាដល់មករា | លប | ៤គ្រឿង/គ្រួសារ | ១១គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍និងអ្នក |

| | | | | |
|---|---|---|---|---|
| | | | | មិនសមាជិកសហគមន៍ |
| សីហាដល់វិច្ឆិកា | សន្ទូចរនង | ១០០/គ្រួសារ | ៤គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| ពេញមួយឆ្នាំ | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| សីហាដល់វិច្ឆិកា | សន្ទូចបង្កៃ | ៤០ផ្លែ/គ្រួសារ | ៣គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| សីហាដល់តុលា | លាន់ | ២០គ្រឿង/គ្រួសារ | ៣គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| សីហាដល់តុលា | ថ្នង(ដងដៃ) | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| សីហាដល់វិច្ឆិកា | ទ្រូ | ៤គ្រឿង/គ្រួសារ | ៩គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |

**គ.២ ផែនការកែលម្អកន្លែងនេសាទសហគមន៍**

ផែនការកែលម្អដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម - បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងអភិរក្សត្រីមេពូជក្នុងអាងទឹកជ្រោយចេក | ១ហិកតា | ៥០មx១០០មx៣ម= ១៥.០០០ម³ | ប្រជុំផ្សព្វផ្សាយ | ១០០ | ២០១៧ - ២០១៨ |
| | | | កំណត់ទីតាំង | ១០០ | ២០១៧ - ២០១៨ |
| | | | គ្រឿងចក្រស្ដារឡើងវិញ អាចម៍ដីរៀបចំជើងទេរទំនប់ | ១៨.៧៥០ | ២០១៧ - ២០១៨ |
| | | | ដាំនិងថែរក្សាព្រៃលិចទឹក (រាំង ត្រស់) ចំនួន ៤០ដើម | ១០០ | ២០១៧ - ២០១៨ |
| ទំនប់ខណ្ឌរងខាងកើតទំនប់ជ្រោយចេក | ៥មx៥០០ម | (២,៥មx៣ម)x ៥មx២,៥ម= ២កន្លែង | ប្រជុំផ្សព្វផ្សាយ | ១០០ | ២០១៨ - ២០១៩ |
| | | | កំណត់ទីតាំង | ៥០ | ២០១៨ - ២០១៩ |
| | | | សាងសង់ទំនប់ខណ្ឌទប់ទឹកធ្វើពីបេតុង | ១.៥០០ | ២០១៨ - ២០១៩ |
| ប្រឡាយទី២ទំនប់ជ្រោយចេក | ៥មx៥០០ម | ៤មx២០០មx ២ម=១.៦០០ម³ | ប្រជុំផ្សព្វផ្សាយ | ១០០ | ២០១៨ - ២០១៩ |
| | | | កំណត់ទីតាំង | ៥០ | ២០១៨ - ២០១៩ |
| | | | គ្រឿងចក្រស្ដារប្រឡាយឡើងវិញ | ៦០០ | ២០១៨ - ២០១៩ |

### គ.៣ ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អាងទឹកជ្រោយចេក | ១០០ម x ១០០ម | ត្រីមេពូជ | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ (មួយលើក) | ១៥០ | ២០១៧ | ២០១៨ |
| | | | ជួសជុលបង្គោលព្រំស៊ីម៉ង់និងបោះបន្ថែមគ្រាក់ទល់បង្គោល តំបន់អភិរក្ស ចំនួន១៦បង្គោលគ្រាក់ ដោយដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៩៨០ | ២០១៧ | ២០១៨ |
| | | | បោះជំរំបង្គោលគ្រាក់ ចំនួន ៤០ដុំ | ៦០០ | ២០១៧ | ២០១៨ |
| | | | សាងសង់ប៉មយាម ធ្វើពីសរសរបេតុង គ្រឿងដែក ប្រក់ហ្វីប្រូស៊ីម៉ង់ ទំហំ ៤មx៣ម x៤ម | ១.៤០០ | ២០១៧ | ២០១៨ |
| | | | យាមល្បាត/ការពារកន្លែងអភិរក្ស | ៣.០០០ | ២០១៧ | ២០២២ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើងវិញ ដោយដកហូតមកវិញដីព្រៃលិចទឹក ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| ទំនាបលិចទឹកក្នុងស.ន អាងទឹកជ្រោយចេក | ១១២,២២ ហិកតា | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ចែកឯកសារ | ២០០ | ២០១៩ | ២០២០ |
| | | | | ប្រជុំ | ៥៦២ | | |
| | | | បោះបង្គោលព្រំព្រៃលិចទឹក ចំនួន១៣បង្គោល និងសរសេរស្លាកតាមបង្គោលនីមួយៗ | | ៦៥០ | ២០១៩ | ២០២០ |
| | | | ដាំព្រៃលិចទឹកឡើងវិញនិងថែរក្សា (ដើមរាំង សណ្តាញ់ ចំនួន២០០ដើម) | | ៩០០ | ២០១៩ | ២០២០ |

គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ<br>-ផ្សព្វផ្សាយតាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ មិថុនា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ និងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១.៥៦០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញ | ២០១៧ | ២០២២ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការដើម្បីចុះអនុវត្តន៍ តាមស្ថានភាពជាក់ស្ដែង | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តការងារ | ១៦៥ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | ២០១៧ | ២០២២ |
| អនុវត្តផែនការ៖<br>(រៀបចំកំលាំងចុះ បង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ) (៤ដង/ខែ = ២៤០/ដង) ជាប្រចាំ | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៣.៥០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | ២០១៧ | ២០២២ |
| មធ្យោបាយនិងសម្ភារៈ<br>-សាំងនិងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយឹត | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ២.៣៤៤ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការ | ២០១៧ | ២០២១ |
| ទិញទូកម៉ាស៊ីនថ្មីចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត | ១.៣០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការ | ២០១៧ | ២០២១ |

គ៦-ផែនការប្រជុំប្រចាំខែនិងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំប្រចាំខែនិងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្ដាហ៍ទី៣នៃខែ/រៀងរាល់ខែ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត | ៥០០ | -គណៈកម្មការ<br>-ក្រុមល្បាត | ២០១៧ | ២០២២ |
| ប្រជុំជាមួយអាជ្ញាធរឃុំឬស្ថាប័នពាក់ព័ន្ធ (២០-២៦/រៀងរាល់ខែ) | -ទទួលព័ត៌មាន និងផ្ដល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍ឃុំនិងផែនការស្ថាប័នពាក់ព័ន្ធ | ៩០០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ<br>-ស្ថាប័នពាក់ព័ន្ធ | ២០១៧ | ២០២២ |
| សម្ភារៈការិយាល័យ ៖<br>-កំព្យូទ័រ ព្រីនធ័រ<br>-ក្រដាស់ ប៊ិច<br>-ការទំនាក់ទំនង | មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ១.២០០ | គណៈកម្មការ | ២០១៧ | ២០២២ |

គ៧-ផែនការផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល

ផែនការផ្សព្វផ្សាយនិងបណ្ដុះបណ្ដាលត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទដូចមានខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្ដីពីច្បាប់<br>-ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ<br>បទបញ្ជាផ្ទៃក្នុងស.ន<br>ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-ការប្រើប្រាស់និងការទុកដាក់ថ្នាំកសិកម្ម<br>-ភូមិ ឃុំ មានសុវត្ថិភាព | -សមាជិកសហគមន៍នេសាទនិងអ្នកខាងក្រៅមានការយល់ដឹងនិងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការនិងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឲ្យជីវភាពធូរធារ<br>-ការរស់នៅមានសុវត្ថិភាព | ២.៥៨០ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូរ | មេសា-មិថុនា/រៀងរាល់ឆ្នាំ | |

| | | | | | |
|---|---|---|---|---|---|
| -អំពើហឹង្សាក្នុងគ្រួសារ និង<br>-បទពិសោធន៍ដែលទទួលបាន | និងគ្មានអំពើក្នុងគ្រួសារ | | | | |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | មិថុនា ២០១៧ | មិថុនា ២០២១ |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | មករា/ ២០១៧ | មករា ២០២២ |
| ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជនសហគមន៍នេសាទអាងទឹកជ្រោយចេក | មានយុវជនចូលរួមការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ | ៦០០ | សមាជិកសហគមន៍នេសាទ | ២០១៧ | ២០១៨ |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល :<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាស.ន | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ អ្នកពាក់ព័ន្ធ សិស្ស និស្សិត បានយល់ដឹង និងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ១.៤០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ សិស្ស,និស្សិត | ២០១៧ | ២០១៨ |
| វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កំព្យូទ័រ | គណៈសហគមន៍នេសាទ (២នាក់) | ៣២៥ | គណៈកម្មការ ស.ន | មីនា/២០១៨ | |
| វគ្គបណ្តុះបណ្តាលយេនឌ័រ និងការវិភាគយេនឌ័រ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | មករា/២០១៨ | |
| វគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | មិថុនា/២០១៩ | |
| វគ្គបណ្តុះបណ្តាលពីៈ<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ៦៥០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០២០ | |

គ៨- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាល | | | | | |
| បច្ចេកទេសដាំបន្លែ | មានមុខរបរបង្កើនប្រាក់ចំណូល | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ចិញ្ចឹម (ត្រី កង្កែប អន្ទង់) | មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| កែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោកនិងកក់ | មានមុខរបរបង្កើនប្រាក់ចំណូល | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទស្សនាកំសាន្ត | -ក្រុមចុងភៅ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមធ្វើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមរោងលម្ហែ (កញ្ចះ) | ១.០០០ | គណៈកម្មការនិងសមាជិស.ន | ២០១៩ | ២០២១ |
| ទស្សនៈកិច្ចសិក្សា | | ១.៥០០ | គណៈកម្មការនិងសមាជិស.ន | ២០១៩ | ២០២១ |
| ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមដាំបន្លែ | -បង្កើតក្រុមដាំបន្លែដោយស្ម័គ្រចិត្ត<br>-មានបន្លែផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្តនិងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមចិញ្ចឹម (ត្រី កង្កែប អន្ទង់) | -បង្កើតក្រុមមុខរបរដោយស្ម័គ្រចិត្ត<br>-មានផលិតផលជលផលផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្តនិងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៩ | ២០២១ |
| ក្រុមកែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោកនិងកក់ | គណៈសហគមន៍និងសមាជិកនេសាទបង្កើតឡើងជាក់ស្តែង<br>-មានសម្ភារៈកែច្នៃផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៩ | ២០២១ |

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ

ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទអាងទឹកជ្រោយចេក ត្រូវបានរៀបចំឡើងនៅតំបន់អាងទឹកជ្រោយចេកមានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ<br>-លើកដំបូង<br>-ដំណើរការរួច | គណៈសហគមន៍នេសាទ សមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៤០០ | -គណៈកម្មការ និងសមាជិកស.ន<br>-អាជ្ញាធរពាក់ព័ន្ធ<br>-ជំនាញជលផល<br>-ប៉ូលីស | ២០១៧ | ២០១៩ |
| ទស្សនៈកិច្ចសិក្សា | មានបទពិសោធន៍ស្តីពីការរៀបចំកន្លែងទស្សនាកំសាន្ត | ១.០៣៥ | -គណៈកម្មការ និងសមាជិកស.ន<br>-អាជ្ញាធរពាក់ព័ន្ធ<br>-ជំនាញជលផល | ២០១៧ | ២០១៩ |
| រៀបចំទីតាំងទស្សនាកំសាន្ត<br>- ស្លាកសញ្ញាទីតាំងចំនួន១<br>-ដាំដើមឈើចំនួន១០០ដើម<br>-សាងសង់រោងប្រជុំ<br>-រោងផ្ទះស្នាក់នៅចំនួន៤<br>-រោងលម្ហែចំនួន៤<br>-ទូកដឹកជញ្ជូនភ្ញៀវចំនួន៦<br>-ធុងសម្រាមចំនួន៩<br>-បង្គន់អនាម័យ(បុរស/ស្ត្រី)<br>-បណ្តាញអគ្គីសនី<br>-ផលិតសៀវភៅណែនាំ | -ដំណើរការបង្កើតតំបន់ទស្សនាកំសាន្តទទួលបានជោគជ័យ<br>-មានសេវាល្អ ធានាគុណភាព តម្លៃសមរម្យ<br>-មានភ្ញៀវគាំទ្រ | ១២.៩០០ | គណៈកម្មការ | ២០១៧ | ២០២១ |
| បង្កើតក្រុម | -ក្រុមបដិសណ្ឋារកិច្ច<br>-ក្រុមសេវាម្ហូបអាហារ<br>-ក្រុមរោងសម្រាកលម្ហែ<br>-ក្រុមរោងស្នាក់នៅ<br>-ក្រុមអាវពោងហែលទឹក<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមផ្ញើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមលក់ផលិតផលកែច្នៃ<br>-ក្រុមកសិកម្មបង្ហាញនិងដើម្បីទេសភាព | ១.២០០ | គណៈកម្មការនិង សមាជិកស.ន | ២០១៧ | ២០២១ |

| | | | | | |
|---|---|---|---|---|---|
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងរបស់ក្រុមមុខរបរ | មានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមនីមួយៗក្នុងការអនុវត្តន៍ | ៤០០ | គណៈកម្មការ និងសមាជិកស.ន | ២០១៧ | ២០២១ |
| សន្តិសុខ សណ្តាប់ធ្នាប់និងអនាម័យ | ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងតំបន់ទស្សនាកំសាន្ត | ១២០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០២១ |

## គ១០- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ

ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយជ្រើសរើសសមាជិកក្រុមឥណទាន | ក្រុមឥណទានសហគមន៍នេសាទអាងទឹកជ្រោយចេក ត្រូវបានបង្កើតឡើងពីគណៈកម្មការនិងសមាជិកស.ន | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងក្រុមឥណទាន | -មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទាន<br>-មានដំណើរការល្អ (ខ្ចី សង) | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ផ្តល់ឥណទាននិងប្រមូលបដិភាគ | មានទុនសម្រាប់ចាប់ផ្តើមមុខរបរ | ២.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ប្រជុំប្រចាំខែ | -របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ២៧០ | ក្រុមឥណទាន | ២០១៧ | ២០២២ |

## គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ប៉ាន់ស្មានតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមស្រះ (៦គ្រួសារ) | ៣សx១៥មx២០មx២,៥ម | ត្រីអណ្តែង | ៥.០០០ កូន/ឆ្នាំ | ៧៨៧,៥ (១ក=៧០រៀល) | មិថុនា/២០១៨ | ខែកុម្ភៈ/២០២១ |
| | ៣សx១៥មx២០មx២,៥ម | ត្រីប្រា ឆ្អិនទីឡាព្យ៉ា | ៥.០០០ កូន/ឆ្នាំ | ៧៨៧,៥ (១ក=៧០រៀល) | មិថុនា/២០១៨ | ខែកុម្ភៈ/២០២១ |
| ចិញ្ចឹមកង្កែប អន្ទង់តាមអាង (១០គ្រួសារ) | ៥អx២មx១,៥មx១,២ម | អន្ទង់ | | ៦២៥ | ខែធ្នូ/២០១៨ | ខែមេសា/២០២១ |
| | ៥អx២មx១,៥មx១,២ម | កង្កែប | | ៥០០ | ខែធ្នូ/២០១៨ | ខែមេសា/២០២១ |

គ១២- ផែនការសាងសង់ស្តង់លក់ផលិតផលសហគមន៍នេសាទ

ផែនការសាងសង់ស្តង់លក់ផលផលិតផលសហគមន៍នេសាទ នៅចំណុចក្បាលលូត្បូងក្បែរទំនប់ជ្រោយចេក ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
| --- | --- | --- | --- | --- | --- |
| សាងសង់ស្តង់លក់ផលផលិតផលសហគន៍នេសាទ ទំហំ៥ម×៦ម ធ្វើពីកម្រាលឬសាបបេតុង សរសរបេតុង គ្រឿងដែក ប្រក់ស័ង្កសី ដោយមានបង្គន់អនាម័យ | -សមាជិកសហគមន៍នេសាទមានស្តង់លក់ផលផលិតផល<br>-មានការចូលរួមពេញលេញក្នុងការការពារ គ្រប់គ្រងធនធានធម្មជាតិក្នុងស.ន | ៤.៥០០ | គណៈកម្មការ សមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៨ | ២០១៩ |
| បណ្តាញអគ្គីសនី | មានថាមពលអគ្គីសនីបំភ្លឺ | ១០០ | | ២០១៨ | ២០១៩ |
| សម្ភារៈសហគមន៍នេសាទ (ក្តារព័ត៌មាន តុ កៅអី) | មានសម្ភារៈសម្រាប់ស.ន ធ្វើការ | ២៥០ | | ២០១៨ | ២០១៩ |

**គ១៣-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូល ដុល្លា | ផ្សេងៗ |
| --- | --- | --- | --- | --- | --- |
| ភាគទានសមាជិកភាព សហគមន៍នេសាទ | -ផ្សព្វផ្សាយការចូលជាសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន៥០០រៀល/ម្នាក់ | ២០១៧ | ២០២២ | ២០ | ៥០០រៀល/នាក់ (១៦៥នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយដល់សមាជិកស.ន បង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ សមាជិកស.ន ២០០ រៀល/ម្នាក់ | ២០១៧ | ២០២២ | ៤១ | ២០០រៀល/នាក់ (១៦៥នាក់) |
| កម្រៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ | ប្រមូលប្រាក់កម្រៃពី<br>-អ្នកនេសាទមិនមែនជាសមាជិក ១០.០០០រៀល/នាក់/រដូវ(ឆ្នាំ)<br>-អ្នកមកពីក្រៅ ១០០.០០០ រៀល/នាក់/រដូវ(ឆ្នាំ) | ២០១៧ | ២០២២ | ៦.៥៣៧ | -២០% នៃអ្នកនេសាទមិនមែនជាសមាជិក៩៤៣ នាក់ អាចប្រមូលបាននិង<br>-៥០% នៃអ្នកមកពីក្រៅ ៦៧នាក់ |
| សរសេរគម្រោងស្នើសុំថវិកាពី ៖<br>-រាជរដ្ឋាភិបាល<br>-សប្បុរសជន<br>-អង្គការដៃគូរពាក់ព័ន្ធ | -ទំនាក់ទំនងជាមួយស្ថាប័ន និងអង្គការដៃគូរ<br>-សរសេរគម្រោងស្នើសុំថវិកា<br>-តាមដាន | ២០១៧ | ២០២២ | ៧៧.៦០៣ | សរសេរគម្រោងស្នើសុំថវិកាចំណាយ ៥០០ដុល្លា |
| សរុប | | | | ៨៤.២០១ | |

ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការរួមមាន សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារប្រឡាយ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្របច្ចេកទេសនិងថវិការសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលនិងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសម្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនិងស្ថាប័នពាក់ព័ន្ធ
- ទិញទូកម៉ាស៊ីនចំនួន១គ្រឿងសម្រាប់គ្រប់គ្រងនិងថែរក្សា ការពារកន្លែងនេសាទសហគមន៍ ។

## តារាងសង្ខេបផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍**អាងទឹកជ្រោយចេក** រយៈពេល ៥ ឆ្នាំ (២០១៧ ដល់ ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទ | -មាននិរន្តរភាពធនធាន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិងគណៈកម្មការ | ២០១៧ | ២០២២ | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | -ស្វែងរកម្ចាស់ជំនួយ<br>-ប្រជុំផ្សព្វផ្សាយ/កំណត់ទីតាំង<br>-គ្រឿងចក្រស្តារប្រឡាយ<br>-អាចម៍ដីរៀបចំជើងទេរទំនប់<br>-សាងសង់ទំនប់ខណ្ឌទប់ទឹកធ្វើពីបេតុង<br>-ដាំព្រៃលិចទឹក រាំង ត្រស់ | -ត្រីមានទីជម្រក<br>-ព្រៃលិចទឹកបានគង់វង្ស<br>-ត្រីកើន<br>-មានទឹកប្រើប្រាស់ | ២១.៤៥០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០១៩ | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-ជួសជុលបង្គោលព្រំស៊ីម៉ង់និងបោះបន្ថែមឈើគ្រាក់ទល់បង្គោល<br>-ដាក់ស្លាកសញ្ញា<br>-បោះជំរំបង្គោលគ្រាក់<br>-សាងសង់ប៉មយាម | -មានត្រីមេពូជ<br>-ត្រីកើនឡើងវិញ | ៣.១៣០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០១៨ | |
| | យាមល្បាត ការពារ | | ៣.០០០ | | ២០១៧ | ២០២២ | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | ផ្សព្វផ្សាយឱ្យបានទូលំទូលាយ (ចែកឯកសារនិងប្រជុំ) | -ព្រៃលិចទឹកបានគង់វង្ស<br>-ជាជម្រកត្រី កន្លែងត្រីពងកូននិងរកចំណី | ៧៦២ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២០ | |
| | បោះបង្គោលព្រំព្រៃនិងសរសេរស្លាកសញ្ញាតាមបង្គោល | | ៦៥០ | | | | |
| | ដាំព្រៃលិចទឹកឡើងវិញនិងថែរក្សាការពារ | | ៩០០ | | | | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | -ប្រជុំផ្សព្វផ្សាយ<br>-ប្រជុំរៀបចំផែនការល្បាត<br>-អនុវត្តផែនការចុះបង្ក្រាបដល់ទីកន្លែង<br>-យុទ្ធនាការបង្ក្រាបបទល្មើសជលផល | -បទល្មើសថយចុះ<br>-ធនធានព្រៃលិចទឹកនិងត្រីកើនឡើងវិញ<br>-ផលចាប់ត្រីបានច្រើន | ៥.២២៥ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២២ | |
| | ទិញមធ្យោបាយនិងសម្ភារៈប្រើប្រាស់ | មានមធ្យោបាយ សម្ភារៈល្បាត | ៣.៦៤៤ | | ២០១៧ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៦.ផែនការប្រជុំប្រចាំខែ និងទិញសម្ភារៈអនុវត្តន៍ការងារគណៈកម្មការស.ន | -ប្រជុំ<br>-ទិញសម្ភារៈការិយាល័យ | -របាយការណ៍លទ្ធផលសម្រេចបានប្រចាំខែ<br>-មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ២.៦០០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២២ | |
| គ៧.ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល | ផ្សព្វផ្សាយ (ប្រជុំ បិទផ្សាយ ចែកឯកសារ)៖ ជលផល, ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន,ផែនការគ្រប់គ្រងស.ន, ការប្រើប្រាស់និងការទុកដាក់ថ្នាំកសិកម្ម និងបទពិសោធន៍នានាដែលទទួលបាន | -គណៈកម្មការសមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋមានការយល់ដឹង<br>-អាចយកទៅអនុវត្តន៍បាន | ៣.៧៩០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២២ | |
| | បណ្តុះបណ្តាលស្តីពី៖<br>-របាយការណ៍ កំណត់ហេតុ<br>-គម្រោងស្នើសុំនិងការគ្រប់គ្រងថវិកា<br>-ការប្រើប្រាស់កំព្យូទ័រ<br>-ការប្រែប្រួលអាកាសធាតុ<br>-ការគ្រប់គ្រងនិងសារៈសំ ខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋាននលើធនធានធម្មជាតិ | | ៣.២៧៥ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២០ | |
| គ៨.ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍ | បណ្តុះបណ្តាលស្តីពី៖<br>- បច្ចេកទេសដាំបន្លែ<br>-ចិញ្ចឹម(សត្វ ត្រី អន្ទង់ កង្កែប)<br>-កែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោក<br>-ជំនាញផ្តល់សេវាទស្សនាកំសាន្ត<br>-ទស្សនៈកិច្ចសិក្សា | -មានចំណេះដឹងនិងបច្ចេកទេសលើមុខរបរ<br>-អាចអនុវត្តន៍បានក្នុងការប្រកបមុខរបរ | ៦.០០០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បង្កើតក្រុមមុខរបរៈ<br>ក្រុមចិញ្ចឹមសត្វ ត្រី អន្ទង់ កង្កែបនិង<br>ក្រុមដាំបន្លែឬដំណាំចំការ | -មានក្រុមមុខរបរកើតឡើង<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ២.០០០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៨ | ២០២១ | |
| គ៩.ផែនការបង្កើតកន្លែងទស្សនាកំសាន្ត | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-រៀបចំទីតាំងទស្សនាកំសាន្ត<br>-បង្កើតក្រុមមុខរបរ<br>-ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងនៃក្រុម<br>-សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ | -ប្រភពចំណូលដល់សហគមន៍នេសាទ<br>-បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានភ្ញៀវមកកំសាន្ត | ១៦.៤៥៥ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២១ | |
| គ១០.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | -ផ្សព្វផ្សាយជ្រើសរើសអ្នកស្ម័គ្រចិត្ត<br>-បង្កើតក្រុមឥណទានប្រេងម៉ាស៊ូតនិងក្រុមឥណទានប្រាក់សន្សំ<br>-រៀបចំរចនាសម្ព័ន្ធក្រុមឥណទាន<br>-ប្រជុំរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង<br>-ផ្តល់ទុនតម្កល់និងចូលរួមបដិភាគ | -មានក្រុមឥណទាន<br>-មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទាន<br>-មានដំណើរការល្អ(ខ្ចី សង)<br>មានទុនចាប់ផ្តើមមុខរបរ<br>-របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ៣.២៧០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០១៨ | |
| | ប្រជុំប្រចាំខែ | | | | ២០១៧ | ២០២២ | |
| គ១១.នការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ | -ចិញ្ចឹមត្រីតាមស្រះ<br>-ចិញ្ចឹមកង្កែបនិងអន្ទង់តាមរាង<br>-ទិញពូជ | -បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ២.៧០០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៨ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ១២.ផែនការសាងសង់ស្តង់លក់ផលិតផលសហគមន៍នេសាទរោងទឹកជ្រោយចេក | -សាងសង់ស្តង់<br>-រៀបចំបណ្តាញអគ្គីសនី<br>-ទិញសម្ភារៈ<br>-ដំណើរការលក់ផលិតផលស.ន | - សហគមន៍នេសាទមានទីផ្សារសម្រាប់លក់ផលិតផល<br>-មានប្រភពថវិកាសម្រាប់បេឡាសហគមន៍នេសាទ<br>-មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ<br>-មានសម្ភារៈប្រើប្រាស់<br>-សម្រេចបានសកម្មភាពការងារ | ៤.៨៥០ | - ស.ន.អ.ទ.ជ.ច<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ១៣.ផែនការថវិកាទ្រទ្រង់សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- កម្រៃពីអ្នកខាងក្រៅ<br>- សរសេរគម្រោងស្នើសុំរាជរដ្ឋាភិបាល សិប្បុរសជន អង្គការនានា | មានថវិកាអនុវត្តន៍សកម្មភាពគ្រប់គ្រងសហគមន៍នេសាទ | ៨៤.២០៦ | - រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២២ | |

| សកម្មភាព | មិថុនា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | ... | ឧសភា |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | | | | | | | | | | | | | | | | | | |
| គ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈការិយាល័យ | | | | | | | | | | | | | | | | | | |
| គ៧.ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល | | | | | | | | | | | | | | | | | | |
| គ៨.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| គ៩.ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងស.ន | | | | | | | | | | | | | | | | | | |
| គ១០.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | | | | | | | | | | | | | | | | | | |
| គ១១.ផែនការអភិវឌ្ឍន៍វារីវប្បកម្មសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| គ១២.ផែនការសាងសង់ស្តង់សហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| គ១៣.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | |

សូមគោរពជូន
លោកមេឃុំទ្រាន
"ដើម្បីជូនពិនិត្យនិងសម្រួល"
ទ្រាន ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៧
ប្រធានគណៈកម្មការសហគមន៍នេសាទ
អាងទឹកជ្រោយចេក
ភាន ធឿន

លេខ ០១២/១៧
បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម
"ដើម្បីជូនពិនិត្យនិងសម្រួល"
ទ្រាន ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៧
មេឃុំទ្រាន
ម៉ែន សារុន

លេខ ០៤៧ ខន.កច
បានឃើញនិងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម
"ដើម្បីជូនពិនិត្យនិងសម្រួល"
កំពង់ចាម ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៧
នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម
អ៊ុក_សារិន

លេខ...២១៨១...ជផ

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...២០... ខែ...កក្កដា...ឆ្នាំ២០១៧

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលផលផល**

**អេង ជាសាន**

លេខ...៦២០ កសក...

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"

កំពង់ចាម ថ្ងៃទី...២០...ខែ...កក្កដា...ឆ្នាំ២០១៧

ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខេត្តកំពង់ចាម

គីម_សារឿន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

ឈ្មោះសហគមន៍នេសាទ ៖ អាងទឹកជ្រោយចេក
ភូមិ ៖ វាលគ្រៀល ទួលចំបក់ ប្រថង ទ្រាន តាខុង ត្រពាំងតាសុក ប៉ែន និងទួលគ្រាច
ឃុំ ៖ ទ្រាន
ស្រុក ៖ កំពង់សៀម
ខេត្ត ៖ កំពង់ចាម

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម**
**ខណ្ឌរដ្ឋបាលជលផលកំពង់ចាម**
លេខ...១៥០....ខជ.កច

## នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម

## សូមគោរពជូន

## ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

**តាមរយៈ** ៖ លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម

**កម្មវត្ថុ** ៖ សំណើ សុំពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចំនួន០២ សហគមន៍ ៖
- សហគមន៍នេសាទរកាគយ នៅភូមិដំណាក់ល្អិត ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម
- សហគមន៍នេសាទអាងទឹកជ្រោយចេក នៅភូមិប្រថង ឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

**យោង** ៖- អនុក្រឹត្យ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
-ប្រកាសនលេខ ៣១៦ ក្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់វិស័យជលផល ខណ្ឌរដ្ឋបាលជលផលកំពង់ចាម បានខិតខំជំរុញដំណើរការរៀបចំសហគមន៍នេសាទនៅទូទាំងខេត្ត បានយ៉ាងទូលំទូលាយ ដោយមានការចូលរួមយ៉ាង ផុសផុលពីសំណាក់ប្រជាពលរដ្ឋ ហើយមានការគាំទ្រនិងសហការយ៉ាងល្អពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងមានការឧបត្ថម្ភពីអង្គការនានា។ ដំណើរការអនុវត្តន៍របស់សហគមន៍នេសាទទាំងពីរនេះ បច្ចុប្បន្នមិនទាន់មានផែនការគ្រប់គ្រងនៅឡើយ ជាពិសេសផែនការគ្រប់គ្រងជាមូលដ្ឋានគ្រឹះ និងជាយន្តការសម្រាប់ជំរុញដំណើរការគ្រប់គ្រងសហគមន៍នេសាទក្នុងការចូលរួមគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព លើកកំពស់កម្រិតជីវភាពរស់នៅនិងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅ

វិស័យជលផលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដូច្នេះខ្ញុំបាទសូមអនុញ្ញាត **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទាំង ០២ សហគមន៍ ដើម្បីឱ្យមានការទទួលស្គាល់ជាផ្លូវការ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

កំពង់ចាម,ថ្ងៃទី...១៣...ខែ...មិថុនា.....ឆ្នាំ២០១៧

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម**

ហ៊ុក សារិន

លេខៈ ៣៤០/១៧ កសិខ
បានឃើញនិងជម្រាបជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល
" ដើម្បីពិនិត្យនិងសម្រេចដោយអនុគ្រោះ"
កំពង់ចាម,ថ្ងៃទី...០៣.....ខែ...កក្កដា.....ឆ្នាំ២០១៧

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម**
**ប្រធាន**

គឹម សារឿន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ

លេខ:.០៤២.......ន.អ.ស

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**កម្មវត្ថុ** ៖ករណីសំណើសុំពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចំនួន០២គឺ៖

- សហគមន៍នេសាទត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត
- សហគមន៍នេសាទបឹងក្រពិត ឃុំមៀននិងឃុំព្រះធាតុ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ។

**យោង** ៖- អនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

- ប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំពីសហ-គមន៍នេសាទ។

**ជូនភ្ជាប់**៖- លិខិតលេខ ០៩៨ ខរជ.គយ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់ខណ្ឌរដ្ឋបាលជលផលកំពត ស្តីពីសំណើសុំពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រពាំងសង្កែ

- លិខិតលេខ ០៩៨ ខរ.កព ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ របស់ខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ ស្តីពីសំណើសុំពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងក្រពិត ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា សហគមន៍នេសាទត្រពាំងសង្កែ ខេត្តកំពតនិងសហគមន៍នេសាទបឹងក្រពិត ខេត្តត្បូងឃ្មុំ មានការឧបត្ថម្ភគាំទ្រថវិកាពីអង្គការ FAO ហើយមានការសហការសម្របសម្រួលពីអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ខណ្ឌរដ្ឋបាលជលផលកំពតនិងត្បូងឃ្មុំ និងរដ្ឋបាលជលផលថ្នាក់កណ្តាល បានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទាំង២នេះ។ ផែនការគ្រប់គ្រងនេះនឹងជាមូលដ្ឋានគ្រឹះ ដែលជាយន្តការសម្រាប់ជំរុញដល់ដំណើរការគ្រប់គ្រងសហគមន៍នេសាទក្នុងការចូលរួមគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព លើកកំពស់កម្រិតជីវភាពរស់នៅនិងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅវិស័យជលផលរបស់រាជរដ្ឋាភិបាលកម្ពុជា។

អាស្រ័យហេតុនេះសូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ៕

រាជធានីភ្នំពេញ, ថ្ងៃទី 16 ខែ មិថុនា ឆ្នាំ២០១៧

**ប្រធានស្តីទីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ**

(signature) លី វុទ្ធី